# ដើម្បីឱ្យកូនចៅរបស់យើងអាចមើលឃើញព្រះភ័ក្ត្ររបស់ព្រះអង្គសង្គ្រោះ

*ស៊ិស្ទើរ ឆើលរីល ស៊ីឡាន់*
*ប្រធានអង្គការបឋមសិក្សាទូទៅ*

អស់ជាច្រើនឆ្នាំកន្លងទៅ ខ្ញុំបង្រៀនដល់ក្រុមពួកអ្នកដឹកនាំកុមារតូចៗ អំពីរបៀបដើម្បី ផ្តល់មេរៀនដំណឹងល្អខ្លីមួយ ទៅដល់កុមារតូចៗ។ អ្នកដឹកនាំម្នាក់ មានកូនប្រុសតូចរបស់នាងបីនៅលើភ្លៅ។ ខ្ញុំបានកាន់រូបភាពរបស់ព្រះអង្គសង្គ្រោះ នៅក្នុងដៃរបស់ខ្ញុំ ហើយបង្ហាញអំពីរបៀប ដើម្បីនិយាយទៅកាន់កុមារតូចៗ បានចាប់ផ្តើមនិយាយអំពីព្រះយេស៊ូវ។ ក្មេងប្រុសដ៏តូចម្នាក់ លូនចុះពីលើភ្លៅរបស់ម្តាយវា ដើរតេសតាសមករកខ្ញុំ មើលរូបភាពដោយយកចិត្តទុកដាក់ ហើយស្ទាបលើមុខរូបភាពនោះ។ នៅត្រង់ចំនុចនេះក្នុងមេរៀន ខ្ញុំបានសួរសំណួរ "តើរូបនេះជានរណា?" ដោយមានស្នាមញញឹមនៅលើមុខរបស់វា កុមារតូចនោះឆ្លើយថា «ព្រះយេស៊ូវ»។

កុមារតូចនេះ មិនទាន់មានអាយុធំល្មមនឹងចេះនិយាយឈ្មោះខ្លួនឯងផង ប៉ុន្តែវាស្គាល់ច្បាស់នូវរូបភាព និងស្គាល់ឈ្មោះព្រះអង្គសង្គ្រោះ។ នៅពេលខ្ញុំមើលទៅការឆ្លើយយ៉ាងផ្អែមល្ហែមនេះ ខ្ញុំបានគិតអំពីព្រះបន្ទូលរបស់ព្រះអង្គសង្គ្រោះ ពេលទ្រង់មានបន្ទូលថា «ចូរស្វែងរកព្រះភក្រ្តនៃព្រះអម្ចាស់ជានិច្ច ប្រយោជន៍ឱ្យអ្នករាល់គ្នា អាចបានព្រលឹងរបស់ខ្លួន ដោយមានចិត្តអត់ធន់ ហើយអ្នករាល់គ្នានឹងបានជីវិតដ៏នៅអស់កល្បជានិច្ច» (គ. និង ស. 101:38)

តើការស្វែងរកព្រះភ័ក្ត្រនៃព្រះអង្គសង្គ្រោះមានន័យដូចម្តេច? ប្រាកដណាស់ វាមានន័យច្រើនជាងការគ្រាន់តែស្គាល់រូបភាពរបស់ទ្រង់។ ការអញ្ជើញរបស់ព្រះគ្រីស្ទ ដើម្បីស្វែងរកទ្រង់ គឺជាការអញ្ជើញមួយដើម្បីស្គាល់ថាទ្រង់គឺជានរណា តើទ្រង់បានធ្វើអ្វីខ្លះសម្រាប់យើង ហើយតើទ្រង់បានសុំឱ្យយើងធ្វើអ្វីខ្លះ។ ការមករកព្រះគ្រីស្ទ ហើយទីបំផុត ការមើលឃើញព្រះភ័ក្ត្ររបស់ទ្រង់ កើតមានតែនៅពេលយើង ខិតទៅជិតទ្រង់ តាមរយៈសេចក្តីជំនឿ និងសកម្មភាពរបស់យើង។ វាកើតមានតាមរយៈការខិតខំពេញមួយជីវិត។ ដូច្នេះតើយើងស្វែងរកទ្រង់នៅក្នុងជីវិតនេះ ដើម្បីយើងអាចមើលឃើញព្រះភក្ត្ររបស់ទ្រង់ក្នុងជីវិតក្រោយដោយរបៀបណា?

យើងមានដំណើររឿងនៅក្នុងនីហ្វៃទី 3 មានប្រជាជនមួយក្រុម បានមើលឃើញព្រះភក្ត្រ របស់ព្រះអង្គសង្គ្រោះ នៅក្នុងជីវិតនេះ ដោយពិត។ ហើយខណៈពេលដែលយើងមិនអាចមើលឃើញទ្រង់នាពេលនេះ នោះប្រហែលជាយើង អាចរៀនមកពីបទពិសោធន៍របស់ពួកគេ។ បន្ទាប់ពីការសុគតរបស់ព្រះអង្គសង្គ្រោះ ទ្រង់បានយាងទៅជួបប្រជាជន ទាំងនេះ បានបង្រៀន ហើយប្រទានពរដល់ពួកគេ។ ហើយបន្ទាប់មក «ហើយហេតុការណ៍បានកើតឡើងថា ទ្រង់បានបញ្ជាពួកគេនាំកូនក្មេងតូចៗមករកទ្រង់» (នីហ្វៃទី 3 17:

11)

វាគឺជាការទទួលខុសត្រូវដ៏ពិសិដ្ឋរបស់យើង ក្នុងនាមជាឪពុកម្តាយ និងអ្នកដឹកនាំ នៃជំនាន់កំពុងពេញវ័យនេះ របស់កូនតូចៗ ដើម្បីនាំពួកគេទៅរកព្រះអង្គសង្គ្រោះ ដើម្បីពួកគេអាចមើលឃើញព្រះភក្ត្ររបស់ទ្រង់ និងព្រះភក្ត្ររបស់ព្រះវរបិតាសួគ៌របស់យើងផងដែរ។ នៅពេលយើងធ្វើ នោះយើងកំពុងតែនាំខ្លួនយើងទៅផងដែរ។

មានសំណួរជាថ្មីទៀតថា តើយើងអាចធ្វើការនេះដោយរបៀបណា ជាពិសេសនៅក្នុងពិភពលោកមួយដែលពោរពេញទៅដោយការរំខាននោះ? នៅក្នុងនីហ្វៃទី 3 ឪពុកម្តាយទាំងនេះ ស្រឡាញ់ព្រះអម្ចាស់ ពួកគេជាពួកអ្នកជឿ។ ពួកគេមានសេចក្តីជំនឿទៅលើអព្ភូតហេតុទាំងឡាយ ដែលព្រះ យេស៊ូវបានសម្តែង។ ពួកគេស្រឡាញ់កូនៗរបស់ពួកគេ។ ពួកគេបានប្រមូលផ្តុំកូនៗឱ្យស្តាប់ព្រះបន្ទូល របស់ព្រះអម្ចាស់ ហើយគោរពតាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ ដើម្បីនាំកូនតូចៗមករកទ្រង់។

បន្ទាប់ពីកូនតូចៗត្រូវបាននាំទៅ ព្រះគ្រីស្ទបានសុំឱ្យឪពុកម្តាយទាំងឡាយលុតជង្គង់ចុះ។ បន្ទាប់មកទ្រង់បានធ្វើសម្រាប់ពួកគេ ដូចជាទ្រង់បានធ្វើសម្រាប់យើងទាំងអស់គ្នាដែរ។ ទ្រង់បានអធិស្ឋាន ទៅកាន់ព្រះវរបិតាសម្រាប់ពួកគេ ហើយនៅពេលទ្រង់បានអធិស្ឋាន នោះគេបាននិយាយថាព្រះបន្ទូលទាំងនោះ «មហិមា និងដ៏គួរឱ្យអស្ចារ្យណាស់» ដែលមិនអាចពិពណ៌នាបាន។ តាមរយៈការមករកព្រះអង្គសង្គ្រោះ ហើយទទួលយកដង្វាយធួនរបស់ទ្រង់ នោះឪពុកម្តាយទាំងនេះ ត្រូវបានពង្រឹងឱ្យធ្វើអ្វីៗទាំងអស់ដែលចាំបាច់ ដើម្បី «នាំ» កូនចៅរបស់ពួកគេ។

រឿងផ្សេងទៀត ដែលព្រះគ្រីស្ទបានសុំឱ្យឪពុកម្តាយទាំងនេះធ្វើ គឺមាននៅក្នុងនីហ្វៃទី 3 22:13៖ «ឯកូនចៅទាំងប៉ុន្មានរបស់អ្នក នឹងធ្វើជាសិស្សរបស់ព្រះអម្ចាស់ ហើយវារាល់គ្នានឹងមានសន្តិសុខជាបរិបូរណ៍»។

ហេតុដូច្នេះហើយ ដោយការធ្វើតាមបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេជាមួយព្រះអង្គសង្គ្រោះ នោះឪពុកម្តាយពួកសាសន៍នីហ្វៃទាំងនេះ បានបង្រៀនកូនចៅរបស់ពួកគេអំពីទ្រង់។ ពួកគេបានបង្រៀន ដល់កូនៗឱ្យស្រឡាញ់ព្រះអម្ចាស់។ ពួកគេបានបង្រៀនកូនៗអំពីដំណឹងល្អរបស់ទ្រង់។ ពួកគេបានបង្រៀនដល់កូនអំពីរបៀបរស់នៅតាម។ ពួកគេបានបង្រៀនដល់កូនៗយ៉ាងល្អ ដើម្បីឱ្យមានសេចក្តីសុចរិត និងសេចក្តីសុខសាន្តមាននៅលើទឹកដី អស់រយៈពេល 200 ឆ្នាំ។

ឥឡូវនេះ ខ្ញុំចង់សុំឱ្យអ្នកមើលនៅជុំវិញខ្លួនរកមនុស្សដែលអ្នកស្រឡាញ់។ នេះគឺជារឿងសំខាន់បំផុត--- គ្រួសាររបស់យើង។ ខ្ញុំប្រាកដថា អ្នកចង់បានគ្រួសារនេះធ្វើជាគ្រួសាររបស់អ្នកដ៏អស់កល្បជានិច្ច លើសជាងអ្វីៗទាំងអស់។ ដំណើររឿងនៅក្នុងនីហ្វៃទី 3 អាចជួយយើងនាំកូនចៅរបស់យើង ទៅកាន់ទ្រង់

ដោយសារតែវាផ្តល់ជាគំរូដល់យើងធ្វើតាម។ ទីមួយ យើងត្រូវតែស្រឡាញ់ព្រះអម្ចាស់ ឱ្យអស់ពីដួងចិត្តរបស់យើង ហើយយើងត្រូវតែស្រឡាញ់កូនៗរបស់យើង។ ទីពីរ យើងត្រូវតែប្រែក្លាយជាគំរូដ៏សក្តិសមមួយចំពោះពួកគេ ដោយការបន្តស្វែងរកព្រះអម្ចាស់ និងព្យាយាមរស់នៅតាមដំណឹងល្អ។ ទីបី យើងត្រូវតែបង្រៀនដល់កូនៗរបស់យើងអំពីដំណឹងល្អ និងអំពីរបៀបដើម្បីរស់នៅតាមការបង្រៀនដំណឹងល្អ។

ការធ្វើតាមគំរូដើម្បីនាំកូនៗរបស់យើងមករកព្រះអង្គសង្គ្រោះនេះ គឺជាដំណើរការមួយ។ ចូរក្រឡេកមើលគំរូម្តងទៀត។ ទីមួយយើងត្រូវតែរៀនរបៀបដើម្បីស្រឡាញ់ព្រះអម្ចាស់ និងស្រឡាញ់គ្រួសាររបស់យើង។ រឿងនេះត្រូវការពេលវេលា និងបទពិសោធន៍ សេចក្តីជំនឿ និងតម្រូវឱ្យមានការបំរើដោយមិនគិតពីខ្លួនឯង។ បន្ទាប់មក នៅពេលយើងពោរពេញទៅដោយសេចក្តីស្រឡាញ់ ចំពោះព្រះអម្ចាស់ នោះយើងអាចមានសេចក្តីស្រឡាញ់។ ទ្រង់អាចមានព្រះកន្សែងចំពោះអ្វីដែលយើងធ្វើ ប៉ុន្តែទ្រង់ស្រឡាញ់យើង ហើយតែងតែគង់នៅជិតដើម្បីជួយយើង។ នោះគឺជារបៀបដែលយើងត្រូវតែរៀនស្រឡាញ់កូនៗរបស់យើង។

ទីពីរ យើងត្រូវតែប្រែក្លាយជាគំរូដ៏សក្តិសម។ នេះក៏ជាដំណើរការមួយផងដែរ។ បើសិនជាយើងចង់ឱ្យកូនៗរបស់យើងមករកព្រះគ្រីស្ទ ដើម្បីឱ្យពួកគេអាចមើលឃើញព្រះភក្ត្រទ្រង់ វាគឺជាការសំខាន់ ដែលយើងស្វែងរកផងដែរ។ យើងត្រូវតែដឹងរបៀប ដើម្បីបង្ហាញទៅកាន់កូនៗ។ យើងត្រូវតែរៀបចំជីវិតរបស់យើងផ្ទាល់ ឱ្យមានរបៀបរៀបរយ ដើម្បីឱ្យកូនៗអាចមើលមកយើង ហើយធ្វើតាម។ យើងអាចសួរថា «តើកូនៗរបស់ខ្ញុំមើលឃើញអ្វីខ្លះ នៅពេលពួកគេមើលមកទឹកមុខរបស់ខ្ញុំ? តើពួកគេមើលឃើញរូបភាពព្រះអង្គសង្គ្រោះនៅលើមុខរបស់ខ្ញុំ ដោយសារតែរបៀបដែលខ្ញុំរស់នៅក្នុងជីវិតរបស់ខ្ញុំឬទេ?»

ឥឡូវនេះ សូមចងចាំថា គ្មានយើងរាល់គ្នាណាម្នាក់ នឹងមានគំរូល្អឥតខ្ចោះសម្រាប់កូនៗរបស់យើងទេ ប៉ុន្តែយើងទាំងអស់គ្នា អាចប្រែក្លាយជាឪពុកម្តាយ និងអ្នកដឹកនាំដែលមានភាពសក្តិសម។ ការព្យាយាមរបស់យើង ដើម្បីមានភាពសក្តិសម គឺជាគំរូមួយទៅហើយ។ យើងអាចដឹង នៅពេលយើងធ្លាក់ចុះម្តងម្កាល ប៉ុន្តែយើងអាចបន្តនៅព្យាយាម។ ជាមួយនឹងព្រះអម្ចាស់ និងតាមរយៈព្រះអម្ចាស់ នោះយើងអាចត្រូវបានពង្រឹង ឱ្យធ្វើជាមនុស្សដែលយើងចាំបាច់ត្រូវប្រែក្លាយ។ យើងអាចធ្វើអ្វីដែលយើងចាំបាច់ត្រូវធ្វើ។

ហើយទីបី យើងមានដំណើរការនៃការនាំកូនៗរបស់យើងមករកព្រះអង្គសង្គ្រោះ តាមរយៈការបង្រៀនដល់ពួកគេ អំពីសេចក្តីពិតនៃដំណឹងល្អ មកពីព្រះគម្ពីរ និងពួកព្យាការី ហើយជួយពួកគេឱ្យដឹង និងទទួលស្គាល់ព្រះវិញ្ញាណ។ សូម្បីតែក្មេងតូចៗក៏អាចយល់ និងទទួលយករឿង ទាំងឡាយដែលមានលក្ខណៈអស់កល្ប ផងដែរ។ ពួកគេស្រឡាញ់ព្រះគម្ពីរ ហើយពួកគេស្រឡាញ់ព្យាការី។ ពួកគេចង់ក្លាយជាមនុស្សល្អពីកំណើត។ វាអាស្រ័យលើយើងក្នុងការជួយពួកគេរក្សាទំនាក់ទំនងនោះ

ដើម្បីឱ្យស្ថានសួគ៌បើកចំហរ។ វាអាស្រ័យទៅលើយើងដើម្បីការពារពួកគេពីឥទ្ធិពល និងការរំខានពីព្រះវិញ្ញាណ។ យើងអាចរកឃើញជំនួយ និងការដឹកនាំនៅក្នុងព្រះគម្ពីរ។ បន្ទាប់មក យើងអាចបង្រៀនកូនចៅរបស់យើង ឱ្យស្វែងរកចម្លើយផ្ទាល់ខ្លួននៅទីនោះ។ យើងអាចបង្រៀនដល់ពួកគេនូវគោលការណ៍ត្រឹមត្រូវ ហើយជួយពួកគេឱ្យអនុវត្តនៅក្នុងជីវិត។ យើងអាចដឹកនាំពួកគេ ឱ្យដើរឆ្ពោះទៅព្រះវិញ្ញាណដើម្បីពួកគេអាចទទួលបានសាក្សីផ្ទាល់ខ្លួនរបស់ពួកគេអំពីសេចក្តីពិត ដែលពួកគេកំពុងតែរៀន។ យើងអាចជួយពួកគេស្វែងរកក្តីអំណរក្នុងការរស់នៅតាមដំណឹងល្អ។ ការណ៍នេះនឹងស្ថាបនាគ្រឹះ នៃសេចក្តីជំនឿ និងការគោរពប្រតិបត្តិដ៏រឹងមាំមួយ នៅក្នុងជីវិតរស់នៅរបស់ពួកគេ ដែលនឹងពង្រឹងពួកគេ។

ឥឡូវនេះ រឿងទាំងអស់នេះមិនមែនកើតមកដោយងាយស្រួលនោះទេ។ ដំណើររឿងពួកសាសន៍ នីហ្វៃបានប្រាប់ថា  គ្រួសារទាំងនោះ មានសេចក្តីសុខសាន្តរយៈពេល 200 ឆ្នាំ។ ប៉ុន្តែវាពិតជា ត្រូវការនូវការខិតខំប្រឹងប្រែងយ៉ាងខ្លាំង។ វាត្រូវការនូវការខិតខំ ការអត់ធ្មត់ និងសេចក្តីជំនឿយ៉ាងច្រើន ប៉ុន្តែគ្មានអ្វីដែលសំខាន់ ឬជារង្វាន់ជាងនេះទេ។ ហើយព្រះអម្ចាស់ នឹងគង់នៅចាំជួយយើង ពីព្រោះទ្រង់ស្រឡាញ់កូនតូចៗទាំងនេះច្រើនជាងយើង។ ទ្រង់ស្រឡាញ់ពួកគេ ហើយទ្រង់នឹងប្រទានពរដល់ពួកគេ។

អ្នកនឹងចងចាំថា ទ្រង់បានប្រទានពរដល់កូនតូចៗសាសន៍នីហ្វៃ ម្នាក់ៗ ហើយអធិស្ឋានសម្រាប់ពួកគេ។ បន្ទាប់មក «ទ្រង់មានបន្ទូលទៅហ្វូងមនុស្សថា៖ មើលន៍ កូនតូចៗរបស់អ្នករាល់គ្នា។ ហើយនៅពេលពួកគេក្រឡេកមើលទៅ នោះពួកគេបានសម្លឹងមើលទៅលើផ្ទៃមេឃ ហើយឃើញផ្ទៃមេឃបើកចំហរ ហើយពួកគេឃើញពួកទេវតា ហោះចុះមកពីស្ថានសួគ៌ ហាក់បីដូចជានៅកណ្តាលភ្លើង ហើយពួកទេវតាក៏ចុះមកហែរហមជុំវិញពួកកូនក្មេងទាំងនោះ រីឯភ្លើងក៏ព័ទ្ធជុំវិញពួកវា ហើយពួកទេវតាបានធ្វើការងារបំរើដល់ពួកកូនក្មេង»។ (នីហ្វៃទី 3 17:23—24)។

តើកូនតូចៗរបស់យើង អាចទទួលបទពិសោធន៍នៃពរជ័យដូចគ្នានេះនាសព្វថ្ងៃនេះដោយរបៀបណា? អែលឌើរ អិម រ័សសុល បាឡឺដ បានមានប្រសាសន៍ថា «ជាក់ស្តែងណាស់ថា យើងរាល់គ្នា ដែលមានកូនដ៏មានតម្លៃ គឺត្រូវបានប្រគល់ឱ្យនូវកិច្ចការពិសិដ្ឋ និងថ្លៃថ្នូ ត្បិតយើងជាមនុស្សដែលព្រះបានតែងតាំងឱ្យឱបក្រសោបកូនៗនៅសព្វថ្ងៃនេះ ដោយក្តីស្រឡាញ់ និងដោយភ្លើងនៃសេចក្តីជំនឿ ហើយយល់ថាពួកគេជានរណា»។ (អែលឌើរ M. Russell Ballard «Great Shall Be the Peace of Thy Children» Ensign ខែ មេសា ឆ្នាំ 1994 ទំព័រ 59-61)

បងប្អូនប្រុសស្រី យើងគឺជាទេវតា ដែលព្រះវរបិតាសួគ៌បានបញ្ជូនមកសព្វថ្ងៃនេះ ដើម្បីប្រទានពរដល់កូនៗ ហើយយើងអាចជួយពួកគេថា ថ្ងៃណាមួយពួកគេអាចមើលឃើញព្រះភក្ត្ររបស់ព្រះអង្គសង្គ្រោះ នៅពេលយើងបង្រៀនគោលការណ៍ទាំងឡាយនៃដំណឹងល្អ ហើយបំពេញក្នុងគេហដ្ឋានរបស់យើង ដោយក្តីអំណរ នៅក្នុងការរស់នៅតាមគោលការណ៍ទាំងនោះ។ យើងអាចមកស្គាល់ទ្រង់ជាមួយគ្នា។ យើងអាច

ដឹងអំពីសេចក្តីស្រឡាញ់របស់ទ្រង់ និងពរជ័យទាំងឡាយរបស់ទ្រង់។ ហើយតាមរយៈទ្រង់ យើងអាចត្រឡប់ទៅរកវត្តមានរបស់ព្រះវរបិតា។ យើងធ្វើការណ៍នេះ នៅពេលយើងស្មគ្រ័ចិត្តគោរពប្រតិបត្តិ ស្មោះត្រង់ និងឧស្សាហ៍ព្យាយាមនៅក្នុងការធ្វើតាមការបង្រៀនរបស់ទ្រង់។

«ប្រាកដមែន ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដូច្នេះថា ហេតុការណ៍នឹងកើតឡើងថា មនុស្សគ្រប់រូបដែលលះបង់ចោលអំពើបាបទាំងឡាយរបស់ខ្លួន ហើយមករកយើង ហើយអំពាវនាវ ដល់ព្រះនាមរបស់យើង ហើយគោរពតាមសម្លេងរបស់យើង ហើយកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់យើង នោះនឹងបានឃើញព្រះភក្ត្ររបស់យើង ហើយស្គាល់ថាយើងជាព្រះ» (គ. និងស. 93:1)។

បងប្អូនប្រុសស្រី ខ្ញុំដឹងថាព្រះមានព្រះជន្មរស់ ព្រះយេស៊ូវគ្រីស្ទ គឺជាព្រះរាជបុត្រារបស់ទ្រង់ ជាព្រះអង្គសង្គ្រោះ និងព្រះប្រោសលោះរបស់យើង។ ទ្រង់បានអញ្ជើញយើងឱ្យមករកទ្រង់ ហើយបានបញ្ជា យើងឱ្យនាំកូនចៅរបស់យើងមក ដើម្បីយើងអាចមើលឃើញព្រះភក្ត្ររបស់ទ្រង់ជាមួយគ្នា ហើយរស់នៅជំអស់កល្បជានិច្ចជាមួយទ្រង់ និងជាមួយព្រះវរបិតាស្ថានសួគ៌របស់យើង។ នេះគឺជាការអធិស្ឋានរបស់ខ្ញុំសុំឱ្យយើងទាំងអស់អាចធ្វើការ ដើម្បីទទួលបានពរជ័យដ៏មហិមានេះ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន។